# គន្លឹះ៤យ៉ាងដើម្បីឱ្យទូរស័ព្ទអ្នកមានសុវត្ថិភាព

## ១-ចាក់សោរអេក្រង់

ការចាក់សោរអេក្រង់ទូរស័ព្ទអាចជួយការពារអ្នកដទៃពីការលួចចូលទៅប្រើទូរស័ព្ទអ្នកដោយគ្មានការអនុញ្ញាតពីអ្នក។

## ២- ធ្វើបច្ចុប្បន្នភាព

ទោះជាអ្នកប្រើទូរស័ព្ទម៉ូដែលណាក៏ដោយ អ្នកចាំបាច់ត្រូវធ្វើបច្ចុប្បន្នភាពប្រព័ន្ធប្រតិបត្តិការ និងគ្រប់កម្មវិធីនៅក្នុងទូរស័ព្ទអ្នក ដើម្បីទទួលបានមុខងារសុវត្ថិភាពថ្មីៗនៅក្នុងទូរស័ព្ទអ្នក។



## ៣- ធ្វើកូដនីយកម្ម

ការធ្វើកូដនីយកម្មទូរស័ព្ទ ប្រៀបដូចជាការចាក់សោរទិន្នន័យនៅក្នុងទូរស័ព្ទអ្នកអីចឹង។ ប្រសិនបើអ្នកបាត់ទូរស័ព្ទ នោះរាល់ទិន្នន័យក្នុងទូរស័ព្ទរបស់អ្នកនឹងត្រូវបានចាក់សោរ អ្នកផ្សេងមិនអាចបើមើល ឬយកទិន្នន័យនោះទៅប្រើបានទេ។

## ៤- ប្រយ័ត្នចំពោះការប្រើអ៊ីនធឺណែត

ការភ្ជាប់អ៊ីនធឺណែតនៅកន្លែងសាធារណៈ ដូចជា នៅហាងកាហ្វេ សណ្ឋាគារ ជាដើម មិនមានសុវត្ថិភាពទេ ព្រោះអ្នកមិនអាចដឹងថា អ្នកណាជាអ្នកគ្រប់គ្រងបណ្ដាញនោះ។ អ្នកផ្សេងអាចដឹងពីសកម្មភាពនៃការប្រើអ៊ីនធឺណែតរបស់អ្នក ព័ត៌មានទាក់ទងនឹងការចូលប្រើគណនី រួមមាន អ៊ីមែល និងពាក្យសម្ងាត់ជាដើម។ល។ ប្រសិន បើអ្នកចាំបាច់ត្រូវតែប្រើអ៊ីនធឺណែត អ្នកគួរតែអ៊ីនធឺណែត 3G / 4G ចេញពីទូរស័ព្ទអ្នក ឬប្រើវីភីអ៊ិន (VPN)។

ធ្វើបច្ចុប្បន្នភាពចុងក្រោយ ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៩

DigitalHub.COM